J Trust Royal Bank

# លក្ខខណ្ឌដោយឡែកចំពោះការប្រើប្រាស់បណ្ណឥណទាន របស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក

មានសុពលភាពចាប់ពី ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៦

## មាតិកា


ការផ្តល់បណ្ណ....4

1. ភាគពុកិច្ចបង់ប្រាក់របស់ម្ចាស់បណ្ណ....4

ការប្រើប្រាស់បណ្ណ....5

2. ការប្រើប្រាស់បណ្ណដែលត្រូវបានហាមឃាត់....5
3. ប្រតិបត្តិការទិញទំនិញ....5
4. ប្រតិបត្តិការសាច់ប្រាក់....5
5. ការប្រើប្រាស់លេខសម្ងាត់ផ្ទាល់ខ្លួន....6
6. របាយការណ៍....6
7. កម្មសិទ្ធិនៃបណ្ណ....6
8. ការណែនាំរបស់ម្ចាស់បណ្ណ....7
9. ការធ្វើបច្ចុប្បន្នភាពព័ត៌មាន....7
10. ករណីលើកលែង....8
11. បណ្ណដែលបាត់បង់ ឬចោរលួច....8
12. ការធ្វើប្រតិបត្តិការបង្វិលប្រាក់សងវិញ....9
13. រយៈពេលកំណត់នៃការធ្វើប្រតិបត្តិការបង្វិលប្រាក់សងវិញ....9
14. ការបញ្ចប់ការប្រើប្រាស់បណ្ណ ដោយម្ចាស់បណ្ណ....9
15. ការជូនដំណឹងដោយធនាគារ....9

ចំនួនកំណត់នៃទំហំឥណទាន....10

16. ការលើសចំនួនកំណត់....10
17. ការបង្កើន/បន្ថយចំនួនកំណត់នៃទំហំឥណទាន....10

វិធីទូទាត់ប្រាក់....10

18. ម្ចាស់បណ្ណ ត្រូវទូទាត់រាល់ថ្លៃប្រតិបត្តិការ កម្រៃ និងថ្លៃសេវាផ្សេងៗទៅឱ្យធនាគារឱ្យបានមុន ឬនៅថ្ងៃផុតកំណត់ ដែលមានបញ្ជាក់នៅក្នុងរបាយការណ៍....10
19. ចំនួនទឹកប្រាក់ត្រូវទូទាត់....11




Classified as Internal

20. ការអនុវត្តការទូទាត់ប្រាក់ ....... 11
21. ប្រតិបត្តិការរូបិយប័ណ្ណបរទេស ....... 11
22. អត្រាការប្រាក់ ....... 12
23. រយៈពេលមិនគិតការប្រាក់ចំពោះប្រតិបត្តិការទិញទំនិញ ....... 12
24. ការគណនាអត្រាការប្រាក់ ....... 12
25. ករណីបំពានកិច្ចព្រមព្រៀង ....... 12
ថ្លៃសេវា ....... 13
26. ថ្លៃសេវា ....... 13
លក្ខខណ្ឌផ្សេងៗ ....... 14
27. បណ្ណបន្ថែម ....... 14
28. ការកែប្រែលក្ខខណ្ឌដោយឡែកនេះ ....... 15
29. ការលើកលែងចំពោះការបំពានកិច្ចព្រមព្រៀង ....... 15
30. ស្វ័យភាពនៃលក្ខខណ្ឌ ....... 15
31. បណ្ណដែលមានកិច្ចធានា ....... 15
32. ពន្ធ ....... 16
33. ពន្យល់ពាក្យ ....... 16



Classified as Internal

# លក្ខខណ្ឌដោយឡែកចំពោះការប្រើប្រាស់បណ្ណឥណទានរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក

លក្ខខណ្ឌដោយឡែកចំពោះការប្រើប្រាស់បណ្ណឥណទាននេះ កំណត់លក្ខខណ្ឌក្នុងការផ្តល់បណ្ណដោយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក (ធនាគារ ឬ អ្នកចេញបណ្ណ) និងការប្រើប្រាស់ដោយលោកអ្នក (អតិថិជន ឬម្ចាស់បណ្ណ) ចំពោះបណ្ណឥណទាន។

លក្ខខណ្ឌដោយឡែកនេះ ត្រូវតែអានរួមគ្នាជាមួយលក្ខខណ្ឌទូទៅនៃសេវាកម្មធនាគារ លក្ខខណ្ឌទូទៅនៃគណនីរបស់ធនាគារ និងអាចរួមបញ្ចូល លក្ខខណ្ឌទូទៅនៃគណនីធនាគារ លក្ខខណ្ឌទូទៅនៃសំណុំឥណទាន និងរាល់លក្ខខណ្ឌ និងឯកសារដែលពាក់ព័ន្ធ ដែលឯកសារទាំងអស់បង្កើតបានជាកិច្ចព្រមព្រៀង រវាងគូភាគី (ធនាគារ និងអតិថិជន)។

## ការផ្តល់បណ្ណ

### 1. កាតព្វកិច្ចបង់ប្រាក់របស់ម្ចាស់បណ្ណ

ម្ចាស់បណ្ណ រួមទាំងម្ចាស់បណ្ណចម្បង និងម្ចាស់បណ្ណបន្ថែមទាំងអស់ ត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នាចំពោះការទូទាត់ប្រាក់នៃប្រតិបត្តិការទាំងអស់ និង រាល់ការប្រាក់ ថ្លៃសេវា និងចំណាយទាំងអស់ពាក់ព័ន្ធនឹងគណនីនេះ សម្រាប់ការប្រើប្រាស់បណ្ណ រួមមានជាអាទិ៍ ថ្លៃសេវាដែលមិនអាចដកយកវិញបាន ពន្ធ និងអាករនានាដែលមានចែងក្នុងច្បាប់ រហូតទាល់តែម្ចាស់បណ្ណធ្វើការទូទាត់គ្រប់ចំនួនទៅឱ្យធនាគារ ដោយពុំចាំបាច់ស្នើសុំវិក្កយបត្រដែលមានចុះហត្ថលេខា និងឯកសារយោងនានា។

កាតព្វកិច្ចបង់ប្រាក់របស់ម្ចាស់បណ្ណ នឹងនៅតែបន្តមានប្រសិទ្ធភាព ក្នុងករណីដែលមានការចេញបណ្ណជាថ្មីឡើងវិញ ឬមានការផ្លាស់ប្តូរបណ្ណថ្មីជំនួស ដោយធនាគារ និងនៅក្នុងករណីដែលមានការបញ្ចប់ ដោយហេតុផលណាមួយផងដែរ។

ដោយពុំចាំបាច់ជូនដំណឹងជាមុនទៅឱ្យម្ចាស់បណ្ណ និង ពុំមានហេតុផលក្នុងការធ្វើដូច្នោះ ធនាគាររក្សាសិទ្ធិ និងមានសិទ្ធិគ្រប់គ្រាន់ក្នុងការៈ

- យល់ព្រម ឬបដិសេធការផ្តល់បណ្ណទៅឱ្យម្ចាស់បណ្ណ
- បដិសេធ ឬយល់ព្រមលើប្រតិបត្តិការ
- បញ្ចប់ដំណើរការប្រើប្រាស់បណ្ណរបស់ម្ចាស់បណ្ណ នៅគ្រប់ពេលវេលាទាំងអស់
- បង្កើន ឬបន្ថយចំនួនកំណត់
- បដិសេធក្នុងការផ្តល់បណ្ណម្តងទៀត ការចេញបណ្ណជាថ្មីឡើងវិញ ការផ្លាស់ប្តូរបណ្ណជំនួស ឬការពន្យារពេលបណ្ណ និង
- កែប្រែ កែតម្រូវ ដាក់កំហិត ឬលុបចោលសេវាកម្ម លក្ខខណ្ឌផ្សេងៗដែលទាក់ទងទៅនឹងបណ្ណ និងគណនីរបស់ម្ចាស់បណ្ណ។

ធនាគារ មិនទទួលខុសត្រូវចំពោះសោហ៊ុយ និងសំណងការខូចខាតណាមួយដែលទាមទារដោយម្ចាស់បណ្ណ ក្នុងករណីដែលធនាគារមិនអនុញ្ញាតឱ្យមានប្រតិបត្តិការណាមួយចេញពីគណនីរបស់ម្ចាស់បណ្ណ និង/ឬប្រសិនបើពាណិជ្ជករមិនយល់ព្រមទទួលយកបណ្ណ ទោះបីជាប្រតិបត្តិការនោះស្ថិតនៅក្នុងចំនួនកំណត់ក៏ដោយ។



Classified as Internal

ធនាគារអាចកំណត់ចំនួនប្រតិបត្តិការប្រចាំថ្ងៃ និង/ឬចំនួនទឹកប្រាក់ប្រចាំថ្ងៃនៃប្រតិបត្តិការ ។

ប្រសិនបើធនាគាររកឃើញថាមានសកម្មភាពគួរឱ្យសង្ស័យ ឬមិនប្រក្រតីណាមួយទាក់ទងនឹងគណនីនេះ ធនាគារអាចស្នើសុំឱ្យម្ចាស់បណ្ណទាក់ទងមកកាន់ធនាគារ និង/ឬអាចផ្អាកជាបណ្តោះអាសន្ននូវសិទ្ធិខ្លះ ឬសិទ្ធិទាំងអស់ក្នុងការប្រើប្រាស់បណ្ណ លុះត្រាណាតែធនាគារបានពិនិត្យផ្ទៀងផ្ទាត់រួចរាល់សិន។

ធនាគារអាចអនុញ្ញាតឱ្យមានប្រតិបត្តិការនានាដែលមានចំនួនទឹកប្រាក់សរុបលើស ពីចំនួនកំណត់ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន។ រាល់ហានិភ័យណាមួយ និងហានិភ័យទាំងអស់ដែលអាចកើតឡើង ត្រូវជាបន្ទុករបស់ម្ចាស់បណ្ណ។

## ការប្រើប្រាស់បណ្ណ

### 2. ការប្រើប្រាស់បណ្ណដែលត្រូវបានហាមឃាត់

ម្ចាស់បណ្ណ យល់ព្រម មិនប្រើប្រាស់បណ្ណនេះ ក្នុងគោលបំណងល្មើសច្បាប់ណាមួយ រួមទាំងការបំពានច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់ ច្បាប់វិនិយោគ និងការប្រើប្រាស់រូបិយប័ណ្ណ។

### 3. ប្រតិបត្តិការទិញទំនិញ

ម្ចាស់បណ្ណ អាចប្រើប្រាស់បណ្ណ ដើម្បីធ្វើប្រតិបត្តិការទិញទំនិញមួយ/ច្រើនជាមួយពាណិជ្ជករណាមួយក៏បាន។ ម្ចាស់បណ្ណ ត្រូវតែផ្តល់ព័ត៌មានចាំបាច់ដែលត្រឹមត្រូវ តាមការតម្រូវរបស់ធនាគារ សម្រាប់ធ្វើការសម្រេចចិត្តលើប្រតិបត្តិការនោះ។ ធនាគារ មានសិទ្ធិចុះឥណពន្ធគណនីនូវចំនួនទឹកប្រាក់ណាមួយដែលម្ចាស់បណ្ណបានធ្វើប្រតិបត្តិការ។

ធនាគារមិនទទួលខុសត្រូវចំពោះការដឹកជញ្ជូន ឬ គុណភាពនៃទំនិញ/សេវាកម្មដែលបានធ្វើការទូទាត់តាមរយៈប្រតិបត្តិការទិញទំនិញនោះទេ។ វិវាទណាមួយ និងវិវាទទាំងអស់ដែលទាក់ទងនឹងបញ្ហានេះ គឺជាវិវាទរវាងម្ចាស់បណ្ណនិងពាណិជ្ជករតែប៉ុណ្ណោះ។

ម្ចាស់បណ្ណ ទទួលខុសត្រូវចំពោះរាល់ការទាមទារ ការទូទាត់ និងបញ្ហាពាក់ព័ន្ធផ្សេងទៀត ជាមួយនឹងពាណិជ្ជករដោយផ្ទាល់។

### 4. ប្រតិបត្តិការសាច់ប្រាក់

ម្ចាស់បណ្ណ អាចធ្វើប្រតិបត្តិការសាច់ប្រាក់ តាមរយៈម៉ាស៊ីន ATM និងតាមរយៈស្ថាប័នទូទាត់នានា។ ដើម្បីធ្វើប្រតិបត្តិការសាច់ប្រាក់ ម្ចាស់បណ្ណត្រូវតែប្រើលេខសម្ងាត់ផ្ទាល់ខ្លួន (PIN) ដែលធនាគារបានចេញឱ្យ។ ព័ត៌មានបន្ថែមស្តីអំពីចំនួនកំណត់នៃប្រតិបត្តិការសាច់ប្រាក់ សូមមើលខិតប័ណ្ណព័ត៌មានស្តីពីថ្លៃសេវា និងកម្រៃផ្សេងៗ។

រាល់ប្រតិបត្តិការសាច់ប្រាក់ទាំងអស់ ដែលធ្វើឡើងតាមរយៈបណ្ណនេះ ត្រូវតែធ្វើឡើងដោយម្ចាស់បណ្ណតែប៉ុណ្ណោះ។ ម្ចាស់បណ្ណ មិនទាមទារឱ្យមាន ការបង្ហាញឯកសារយោងអ្វីទាំងអស់ដែលទាក់ទងនឹងប្រតិបត្តិការបណ្ណនេះ ហើយទទួលស្គាល់ថា ការកត់ត្រាទាំងឡាយរបស់ធនាគារ គឺពិតជាត្រឹមត្រូវ។



Classified as Internal

ធនាគាររក្សាសិទ្ធិក្នុងការកំណត់ ចំនួនទឹកប្រាក់នៃប្រតិបត្តិការសាច់ប្រាក់នីមួយៗ និង/ឬចំនួនទឹកប្រាក់សរុបនៃប្រតិបត្តិការសាច់ប្រាក់ទាំងអស់តាមរយៈបណ្ណនេះ ក្នុង ១ ថ្ងៃ ដោយមិនចាំបាច់ជូនដំណឹងជាមុនដល់ម្ចាស់បណ្ណឡើយ ក្នុងចំនួនដែលបានកំណត់ និង/ឬដែលបានកែប្រែ តាមឆន្ទានុសិទ្ធិរបស់ធនាគារ។

## 5. ការប្រើប្រាស់លេខសម្ងាត់ផ្ទាល់ខ្លួន

ម្ចាស់បណ្ណ មិនត្រូវប្រគល់បណ្ណ ឬបង្ហាញលេខសម្ងាត់ផ្ទាល់ខ្លួន (PIN) ទៅឱ្យបុគ្គលណាម្នាក់បានដឹង ដោយមិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីធនាគារឡើយ។ ម្ចាស់បណ្ណ ត្រូវទទួលខុសត្រូវតែម្នាក់ឯងចំពោះប្រតិបត្តិការ ឬការគិតថ្លៃណាមួយដែលកើតចេញពីការប្រើប្រាស់បណ្ណ នៅគ្រប់កាលៈទេសៈ។

## 6. របាយការណ៍

ធនាគារ ត្រូវផ្តល់របាយការណ៍ប្រចាំខែទៅឱ្យម្ចាស់បណ្ណ ទៅតាមអាសយដ្ឋានដែលបានផ្តល់ឱ្យដោយម្ចាស់បណ្ណ។

របាយការណ៍ ត្រូវបានសន្មត់ថាត្រឹមត្រូវ លើកលែងតែមានការជូនដំណឹងពីម្ចាស់បណ្ណទៅឱ្យធនាគារបានដឹងអំពីភាពមិនត្រឹមត្រូវ ក្នុងរយៈពេល ដប់ប្រាំ (១៥) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចេញរបាយការណ៍។ ប្រសិនបើ ធនាគារ តាមឆន្ទានុសិទ្ធិរបស់ខ្លួន រកឃើញថា មានកំហុសពាក់ព័ន្ធនឹងចំនួនទឹកប្រាក់ដែលកំពុងមានវិវាទ ហើយចំនួននេះមិនត្រូវគិតថ្លៃសេវាពីម្ចាស់បណ្ណ ដូច្នេះ ចំនួននេះនឹងត្រូវកត់ត្រាផ្នែកឥណទានទៅក្នុងសមតុល្យដែលនៅសល់។ ចំនួនទឹកប្រាក់អប្បបរមាដែលត្រូវបង់ និង/ឬចំនួនទឹកប្រាក់ដែលត្រូវបង់ផ្សេងទៀត នឹងនៅតែត្រូវទូទាត់ដោយម្ចាស់បណ្ណដដែល។

លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ការមិនបានទទួល ឬការទទួលបានរបាយការណ៍យឺតពេល ក៏មិនអាចឱ្យម្ចាស់បណ្ណរួចផុតពីកាតព្វកិច្ចក្នុងការទូទាត់ចំនួនទឹកប្រាក់អប្បបរមាដែលត្រូវបង់នៅក្នុងគណនី នៅថ្ងៃកំណត់ត្រូវបង់ដូចដែលមានចែងនៅក្នុងរបាយការណ៍បានឡើយ។

ធនាគារ អាចជ្រើសរើស ក្នុងការផ្តល់ ឬ មិនផ្តល់របាយការណ៍ប្រចាំខែទៅឱ្យម្ចាស់បណ្ណ ប្រសិនបើ៖

- ម្ចាស់បណ្ណ មិនបានបំពេញតាមកិច្ចព្រមព្រៀង ក្នុងអំឡុងពេលនៃរបាយការណ៍ និងសម្រាប់អំឡុងពេលនៃរបាយការណ៍ពីរ(២)ចុងក្រោយ ហើយធនាគារបានសម្រេចមិនផ្តល់ និងមិនបានផ្តល់ឥណទានបន្ថែមទៀត
- ម្ចាស់បណ្ណ បានទទួលមរណភាព ឬអសាធនភាព ហើយអ្នកតំណាងផ្ទាល់ខ្លួនរបស់ម្ចាស់បណ្ណ ឬបរធនបាលក្នុងរឿងក្ស័យធន មិនបានស្នើសុំរបាយការណ៍គណនី ឬ
- ធនាគារ មិនតម្រូវឱ្យផ្ញើរបាយការណ៍ទៅឱ្យម្ចាស់បណ្ណ តាមការកំណត់របស់ច្បាប់ ។

ការកំណត់កាលបរិច្ឆេទនៃរបាយការណ៍ គឺជាឆន្ទានុសិទ្ធិរបស់ធនាគារ នឹងត្រូវជូនដំណឹងទៅឱ្យម្ចាស់បណ្ណ បន្ទាប់ពីការចេញបណ្ណ។ របាយការណ៍ នឹងត្រូវបានសន្មត់ថា បានទទួលដោយម្ចាស់បណ្ណ ក្នុងអំឡុងខែប្រតិទិន លើកលែងតែម្ចាស់បណ្ណជូនដំណឹងទៅឱ្យធនាគារថាខ្លួនមិនបានទទួលរបាយការណ៍ ក្នុងរយៈពេលដប់ប្រាំ (១៥) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃរបាយការណ៍។

## 7. កម្មសិទ្ធិនៃបណ្ណ

បណ្ណ គឺជាទ្រព្យសម្បត្តិផ្តាច់មុខរបស់ធនាគារ ហើយម្ចាស់បណ្ណមិនអាចផ្ទេរបណ្ណនេះទៅឱ្យអ្នកផ្សេងបានឡើយ។ បណ្ណ ត្រូវតែចុះហត្ថលេខាភ្លាមៗដោយបុគ្គលដែលមានឈ្មោះនៅលើបណ្ណដែលបានចេញឱ្យ ហើយត្រូវមានសុពលភាព

ចាប់ផ្តើមពីថ្ងៃបណ្ណ ឬថ្ងៃដែលចេញបណ្ណជាថ្មី រហូតដល់ថ្ងៃចុងក្រោយនៃខែផុតកំណត់សុពលភាពដែលមានបញ្ជាក់នៅលើបណ្ណ។

ធនាគារ តាមឆន្ទានុសិទ្ធិរបស់ខ្លួន និងដោយពុំចាំបាច់ជូនដំណឹងជាមុនទៅម្ចាស់បណ្ណ អាចបញ្ឈប់ការផ្តល់បណ្ណ និងការប្រើប្រាស់បណ្ណបានគ្រប់ពេលវេលា មិនថាក្នុងមូលហេតុណាមួយឡើយ។ នៅក្នុងកាលៈទេសៈនេះ ម្ចាស់បណ្ណយល់ព្រមប្រគល់បណ្ណមកវិញ ហើយធនាគារ ឬគ្រឹះស្ថានណាមួយដែលទទួលបានសិទ្ធិពីធនាគារ ក៏មានសិទ្ធិរឹបអូសយកបណ្ណនេះមកវិញផងដែរ។ បន្ទាប់ពីការបញ្ឈប់នេះ សមតុល្យគណនីដែលនៅសល់ រួមមានថ្លៃសេវា និងការប្រាក់ តម្រូវឱ្យធ្វើការទូទាត់ភ្លាមៗ ដោយមិនចាំបាច់ជូនដំណឹង ឬការទាមទារពីធនាគារឡើយ។

ម្ចាស់បណ្ណ មិនត្រូវប្រើប្រាស់បណ្ណ ព្រមទាំងមិនត្រូវអនុញ្ញាតឱ្យអ្នកដទៃប្រើប្រាស់បណ្ណនោះឡើយ ទោះក្នុងមូលហេតុណាក៏ដោយ បន្ទាប់ពីបណ្ណអស់សុពលភាព ឬបន្ទាប់ពីការបញ្ចប់កិច្ចព្រមព្រៀង។ ការបន្តប្រើប្រាស់បណ្ណនេះដោយម្ចាស់បណ្ណ នឹងត្រូវចាត់ទុកថាជាអំពើឆបោកដែលប្រព្រឹត្តដោយម្ចាស់បណ្ណ។

តាមឆន្ទានុសិទ្ធិរបស់ខ្លួន ធនាគារអាចកែប្រែលេខបណ្ណ និង/ឬកាលបរិច្ឆេទផុតកំណត់របស់បណ្ណ នៅពេលដែលចេញបណ្ណសារជាថ្មី ឬពេលចេញបណ្ណថ្មីជំនួសទៅឱ្យម្ចាស់បណ្ណ។ ម្ចាស់បណ្ណ ត្រូវទទួលខុសត្រូវជូនដំណឹងអំពីការផ្លាស់ប្តូរនេះទៅឱ្យភាគីណាមួយដែលម្ចាស់បណ្ណអាចមានការទូទាត់ជាមួយ។ ធនាគារ នឹងមិនទទួលខុសត្រូវលើរាល់ផលវិបាក ឬការខូចខាតណាមួយចំពោះម្ចាស់បណ្ណ ដែលកើតចេញពីប្រតិបត្តិការទាំងឡាយណាដែលត្រូវបានបដិសេធឡើយ បើទោះបីស្ថិតនៅក្រោមលេខបណ្ណពីមុន ឬករណីផ្សេងទៀតក៏ដោយ។

បណ្ណដែលបានបាត់បង់ ឬត្រូវចោរលួច ហើយត្រូវបានរកឃើញវិញដោយម្ចាស់បណ្ណ នោះម្ចាស់បណ្ណត្រូវតែប្រគល់ទៅឱ្យធនាគារវិញ។

ម្ចាស់បណ្ណចម្បង អាចបិទគណនីបានគ្រប់ពេលវេលា ដោយគ្រាន់តែជូនដំណឹងមកធនាគារជាលាយលក្ខណ៍អក្សរ ហើយសមតុល្យគណនីដែលនៅសល់ រួមបញ្ចូលទាំងថ្លៃសេវា និងការប្រាក់ទាំងអស់ទាក់ទងនឹងប្រតិបត្តិការ តម្រូវឱ្យធ្វើការទូទាត់ភ្លាមៗដោយគ្មានការតវ៉ា ឬគ្មានការជូនដំណឹងជាមុនឡើយ។

បន្ទាប់ពីគណនីត្រូវបានបិទដោយម្ចាស់បណ្ណចម្បង ការបន្តប្រើប្រាស់បណ្ណដោយម្ចាស់បណ្ណ មិនត្រូវបានអនុញ្ញាតឡើយ។

## 8. ការណែនាំរបស់ម្ចាស់បណ្ណ

ម្ចាស់បណ្ណ អាចជូនដំណឹង ឬផ្តល់ព័ត៌មានអំពីការណែនាំរបស់ខ្លួនទៅឱ្យធនាគារបានដឹង គ្រប់ពេលវេលា តាមរយៈទម្រង់ជាលាយលក្ខណ៍អក្សរ អ៊ីមែល ទូរសព្ទឬតាមរយៈមធ្យោបាយអេឡិកត្រូនិកផ្សេងទៀតដែលតម្រូវ និងផ្តល់ឱ្យដោយធនាគារ ។

ធនាគារនឹងចាត់ទុកថារាល់ការណែនាំរបស់ម្ចាស់បណ្ណ ពិតជាបានធ្វើឡើងដោយម្ចាស់បណ្ណ និងមានអានុភាពចងកាតព្វកិច្ចចំពោះម្ចាស់បណ្ណ ហើយអ្នកផ្តល់បណ្ណអាចចាត់វិធានការនានាដែលទាក់ទងទៅនឹងការណែនាំនោះ។

## 9. ការធ្វើបច្ចុប្បន្នភាពព័ត៌មាន

ម្ចាស់បណ្ណ ត្រូវជូនដំណឹងដល់ធនាគារជាបន្ទាន់ ក្នុងករណីមានការផ្លាស់ប្តូរព័ត៌មានរបស់ម្ចាស់បណ្ណ រួមទាំងការផ្លាស់ប្តូរអាសយដ្ឋាន លេខទូរសព្ទ ឬអាសយដ្ឋានអ៊ីមែល និងមធ្យោបាយទំនាក់ទំនងផ្សេងទៀតដែលអាចឱ្យធនាគារធ្វើការទាក់ទងជាមួយម្ចាស់បណ្ណបាន។ ។



Classified as Internal

## 10. ករណីលើកលែង

កាតព្វកិច្ចដែលម្ចាស់បណ្ណមានចំពោះធនាគារ ជាកាតព្វកិច្ចដែលត្រូវតែបំពេញដាច់ខាត ហើយរាល់ជម្លោះណាមួយរវាងម្ចាស់បណ្ណជាមួយស្ថាប័ន ឬបុគ្គលណាមួយ មិនត្រូវឱ្យប៉ះពាល់ដល់កាតព្វកិច្ចដែលម្ចាស់បណ្ណមានចំពោះអ្នកផ្តល់បណ្ណឡើយ។

ធនាគារ ត្រូវរួចផុតពីការទទួលខុសត្រូវ ចំពោះការខូចខាត ឬការខាតបង់ផ្សេងៗ ដែលម្ចាស់បណ្ណ អាចទទួលរងដែលបណ្តាលមកពីករណីដូចខាងក្រោម៖

- ការភាន់ច្រឡំរបស់ពាណិជ្ជករក្នុងការទទួលយកបណ្ណ ដោយហេតុផលណាមួយ
- ការមិនដំណើរការ កំហុសណាមួយ ឬការខូចខាតម៉ាស៊ីន ATM និង/ឬឧបករណ៍ទទួលទូទាត់បណ្ណ
- មានការយឺតយ៉ាវ ឬពុំមានលទ្ធភាពក្នុងការអនុវត្តការទទួលខុសត្រូវតាមកិច្ចព្រមព្រៀង ដោយសារការមិនដំណើរការនៃម៉ាស៊ីន ទិន្នន័យ ទំនាក់ទំនង ករណីប្រធានសក្តិ ឬហេតុការណ៍ណាមួយដែលហួសពីសមត្ថភាពគ្រប់គ្រងរបស់ធនាគារ
- មិនមានលទ្ធភាពទទួលបានទិន្នន័យ និង/ឬព័ត៌មានដែលជាប់ទាក់ទងនឹងបណ្ណ
- មានភាពមិនប្រក្រតី ឬការមិនដំណើរការនៃទំនិញ និងសេវាកម្មដែលម្ចាស់បណ្ណបានទិញ ឬបានប្រើប្រាស់

ធនាគារ ត្រូវរួចផុតពីការទទួលខុសត្រូវចំពោះការធ្វើឱ្យប៉ះពាល់កិត្តិយស ឬក៏កេរ្តិ៍ឈ្មោះរបស់ម្ចាស់បណ្ណ ក្នុងករណីដែលបណ្ណត្រូវបានបដិសេធ លុបចោល ឬក៏បណ្ណត្រូវបានដកហូតវិញពីម្ចាស់បណ្ណ ឬក៏កិច្ចព្រមព្រៀងត្រូវបានបញ្ចប់។

## 11. បណ្ណដែលបាត់បង់ ឬចោរលួច

ក្នុងករណីដែលបណ្ណត្រូវបានចោរលួច ឬបាត់បង់ ឬត្រូវបានប្រើប្រាស់ដោយគ្មានការអនុញ្ញាត្តិ ម្ចាស់បណ្ណត្រូវជូនដំណឹងមកធនាគារអំពីអំពើទាំងនោះដោយត្រូវទំនាក់ទំនងមកផ្នែកបម្រើសេវាអតិថិជន ឬជូនដំណឹងមកកាន់ធនាគារជាលាយលក្ខណ៍អក្សរ ឬធ្វើសកម្មភាពណាមួយតាមការណែនាំរបស់ធនាគារ (រួមមានជាអាទិ៍ការផ្អាកបណ្ណតាមរយៈកម្មវិធីទូរសព្ទដៃ) ។ ក្នុងស្ថានភាពជាក់លាក់ណាមួយ ធនាគារអាចតម្រូវឱ្យ ម្ចាស់បណ្ណផ្តល់របាយការណ៍ប៉ូលីសភ្ជាប់ជាមួយការបញ្ជាក់ជាលាយលក្ខណ៍អក្សរអំពីការបាត់បង់/ចោរលួច/ការប្រើប្រាស់មិនត្រឹមត្រូវ/ការបែកធ្លាយ នឹងផ្តល់ព័ត៌មានផ្សេងទៀតដែលធនាគារតម្រូវ។

ប្រសិនបើបណ្ណត្រូវបានបាត់បង់ ឬចោរលួច ឬលេខសម្ងាត់ផ្ទាល់ខ្លួន (PIN) ត្រូវបានបែកធ្លាយ ម្ចាស់បណ្ណ ត្រូវទទួលខុសត្រូវ ចំពោះរាល់ប្រតិបត្តិការបណ្ណដែលបានកើតឡើងដោយសារ ការបាត់បង់/ចោរលួច/ការបែកធ្លាយនោះ រហូតទាល់តែធនាគារបានទទួលការជូនដំណឹងអំពីហេតុការណ៍នោះ។

នៅពេលដែលមានការរាយការណ៍ថាបណ្ណ បានបាត់ ឬត្រូវចោរលួច បណ្ណនោះមិនត្រូវបានប្រើប្រាស់ ប្រសិនបើក្រោយមក ត្រូវបានរកឃើញវិញ។ ម្ចាស់បណ្ណត្រូវកាត់បណ្ណដែលបានរកឃើញវិញនោះជាបំណែកតូចៗ។ រាល់បណ្ណដែលត្រូវបោះចោល ត្រូវតែកាត់ជាបំណែកតូចៗ។ ម្ចាស់បណ្ណ ត្រូវទទួលខុសត្រូវរាល់ការបាត់បង់ ឬការខូចខាតដែលកើតឡើងចេញពីការខកខានក្នុងការធ្វើតាមការណែនាំនេះ។

ថ្លៃសេវាកម្មចេញបណ្ណថ្មីដែលកំណត់ដោយធនាគារ ត្រូវគិតចេញពីគណនីរបស់ម្ចាស់បណ្ណ ដើម្បីធ្វើការទូទាត់ថ្លៃផ្សេងៗដែលទាក់ទងនឹងការចេញបណ្ណថ្មី។



Classified as Internal

## 12. ការធ្វើប្រតិបត្តិការបង្វិលប្រាក់សងវិញ

ម្ចាស់បណ្ណ អាចមានសិទ្ធិក្នុងការធ្វើប្រតិបត្តិការ បង្វិលប្រាក់សងវិញ (គិតថ្លៃឡើងវិញ) បើកាលណាម្ចាស់បណ្ណមានបញ្ហាជាមួយពាណិជ្ជករ។ ឧទាហរណ៍ ម្ចាស់បណ្ណមានសិទ្ធិដើម្បីធ្វើប្រតិបត្តិការបង្វិលប្រាក់សងវិញ នៅពេលដែលពាណិជ្ជករមិនបានផ្តល់ឱ្យម្ចាស់បណ្ណនូវទំនិញ ឬសេវាកម្ម ដែលម្ចាស់បណ្ណបានទិញ។

ក្នុងករណីនេះ ម្ចាស់បណ្ណត្រូវជូនដំណឹងធនាគារ ដែលបានចុះឥណទានក្នុងគណនីរបស់ម្ចាស់បណ្ណចំពោះទឹកប្រាក់ដែលបានធ្វើឥណពន្ធសម្រាប់ប្រតិបត្តិការនោះ ដើម្បីធនាគារអាចធ្វើការស៊ើបអង្កេតនឹងទទួលបានលទ្ធផលដែលអាចបញ្ជាក់បានថាម្ចាស់បណ្ណមានសិទ្ធិក្នុងការធ្វើប្រតិបត្តិការបង្វិលប្រាក់សងវិញ។

## 13. រយៈពេលកំណត់នៃការធ្វើប្រតិបត្តិការបង្វិលប្រាក់សងវិញ

ម្ចាស់បណ្ណត្រូវតែជូនដំណឹងដល់ធនាគារភ្លាមអំពីប្រតិបត្តិការដែលមានបញ្ហា។ វិធានប្រតិបត្តិការរបស់ផលិតផលបណ្ណឥណទានបានកំណត់រយៈពេលផុតកំណត់មួយដែលធនាគារមិនអាចធ្វើប្រតិបត្តិការបង្វិលប្រាក់សងវិញបានឡើយប្រសិនបើផុតអំឡុងពេលកំណត់នេះ។ រយៈពេលកំណត់អប្បបរមា ជាទូទៅគឺ ៧៥ ថ្ងៃ បន្ទាប់ពីប្រតិបត្តិការមានបញ្ហា។ ប្រសិនបើម្ចាស់បណ្ណមិនបានជូនដំណឹងដល់អ្នកផ្តល់បណ្ណទាន់ពេលវេលាទេនោះ អ្នកផ្តល់បណ្ណមិនអាចធ្វើការស៊ើបអង្កេតទៅលើការទាមទាររបស់លោកអ្នកបានទេ ដូច្នេះ ក្នុងករណីនេះ លោកអ្នក ត្រូវទទួលខុសត្រូវចំពោះប្រតិបត្តិការនោះ។

ម្ចាស់បណ្ណត្រូវទទួលខុសត្រូវក្នុងការពិនិត្យផ្ទៀងផ្ទាត់មើលដោយយកចិត្តទុកដាក់លើរបាយការណ៍គណនី របស់លោកអ្នក។ ធនាគារ ពុំទទួលខុសត្រូវចំពោះការបាត់បង់នានា ប្រសិនបើម្ចាស់បណ្ណមិនបានស្នើសុំឱ្យធនាគារធ្វើប្រតិបត្តិការបង្វិលប្រាក់សងវិញ នៅក្នុងរយៈពេលកំណត់ខាងលើ។

## 14. ការបញ្ចប់ការប្រើប្រាស់បណ្ណ ដោយម្ចាស់បណ្ណ

ការបញ្ចប់កិច្ចព្រមព្រៀងតាមការស្នើសុំរបស់ម្ចាស់បណ្ណ ត្រូវធ្វើឡើងបន្ទាប់ពីមានការជូនដំណឹងជាលាយលក្ខណ៍អក្សរពីម្ចាស់បណ្ណចម្បងអំពីឆន្ទៈរបស់ខ្លួនក្នុងការបញ្ចប់គណនី និងទូទាត់សមតុល្យដែលនៅសល់ក្នុងគណនី រួមទាំងការទូទាត់បំណុលផ្សេងៗទៀត។ នៅពេលម្ចាស់បណ្ណចម្បងបានបញ្ចប់កិច្ចព្រមព្រៀង ទាំងម្ចាស់បណ្ណចម្បង និងម្ចាស់បណ្ណបន្ទាប់បន្សំ មិនអាចធ្វើប្រតិបត្តិការណាមួយទាក់ទងនឹងគណនីនេះទៀតទេ។

ការបញ្ចប់កិច្ចព្រមព្រៀង ត្រូវមានប្រសិទ្ធភាព នៅថ្ងៃទី៥ ឬមុនថ្ងៃទី៥ នៃថ្ងៃធ្វើការ បន្ទាប់ពីលក្ខខណ្ឌខាងលើនៅក្នុងប្រការនេះត្រូវបានបំពេញរួចរាល់។

ការធានាណាមួយដែលផ្តល់ដោយម្ចាស់បណ្ណចំពោះគណនី ត្រូវនៅបន្តមានអានុភាព យ៉ាងតិច សាមសិប (៣០) ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទបញ្ចប់កិច្ចព្រមព្រៀង។

## 15. ការជូនដំណឹងដោយធនាគារ

ការជូនដំណឹងដោយធនាគារទៅកាន់ម្ចាស់បណ្ណ តាមរយៈសារអេឡិចត្រូនិក សារជាអក្សរ តេឡេ ទូរសារ អ៊ីមែល ឬតាមប្រព័ន្ធអេឡិចត្រូនិកផ្សេងទៀត ដោយបានប្រើប្រាស់អាសយដ្ឋានទំនាក់ទំនងដែលបានផ្តល់ឱ្យដោយម្ចាស់បណ្ណត្រូវបានចាត់ទុកថាបានផ្ញើទៅដល់ម្ចាស់បណ្ណ។ ក្នុងករណីនេះ ម្ចាស់បណ្ណត្រូវសងជំងឺចិត្ត ការខូចខាត និងចេញមុខទទួលខុសត្រូវជំនួសឱ្យធនាគារ ប្រសិនបើព័ត៌មាន ដែលមាននៅក្នុងការជូនដំណឹងតាមប្រព័ន្ធអេឡិចត្រូនិកនេះត្រូវបានដឹងដល់អ្នកផ្សេងក្រៅពីម្ចាស់បណ្ណ បើទោះបីជាតាមវិធីណាក៏ដោយ។



Classified as Internal

## ចំនួនកំណត់នៃទំហំឥណទាន

### 16. ការលើសចំនួនកំណត់

ម្ចាស់បណ្ណ ត្រូវពិនិត្យតាមដានជាប្រចាំនូវបំណុលសរុបរបស់ខ្លួន ដើម្បីធានាថាមិនលើសពីចំនួនកំណត់ នៅក្នុងរយៈពេលជាក់លាក់ណាមួយ។ ម្ចាស់បណ្ណ ត្រូវទទួលខុសត្រូវចំពោះរាល់ការធ្វើប្រតិបត្តិការ និងថ្លៃសេវាទាំងអស់ ដែលបណ្តាលមកពីការធ្វើឱ្យសមតុល្យបំណុលកើនលើសពីចំនួនកំណត់។ ដោយពុំចាំបាច់ជូនដំណឹងជាមុន ធនាគារ មានសិទ្ធិបដិសេធការធ្វើប្រតិបត្តិការណាមួយ ផ្អាកនូវសិទ្ធិដែលមានលើបណ្ណរបស់ម្ចាស់បណ្ណ និង/ឬ គិតថ្លៃសេវាសម្រាប់ការលើសចំនួនកំណត់ ដែលតម្លៃសេវានេះត្រូវកំណត់ដោយធនាគារ ប្រសិនបើមានការប្រើប្រាស់លើសចំនួនកំណត់នោះ។ ដោយមានការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការណាមួយដែលនាំឱ្យសមតុល្យបំណុលកើនលើសចំនួនកំណត់ នោះធនាគារមិនត្រូវបង្កើនចំនួនកំណត់របស់ម្ចាស់បណ្ណឡើយ។ ធនាគារ អាចទាមទារឱ្យទូទាត់ប្រាក់ដែលលើសពីចំនួនកំណត់នោះ ឬក៏ទាមទារឱ្យបង់សមតុល្យបំណុលទាំងអស់វិញភ្លាមៗ តាមការកំណត់របស់ធនាគារ។ ការប្រើប្រាស់បណ្ណលើសពីចំនួនកំណត់ ដោយគ្មានការយល់ព្រមជាមុនពីធនាគារ អាចត្រូវបានចាត់ទុកថាជា អំពើក្លែងបន្លំ របស់ម្ចាស់បណ្ណ។

### 17. ការបង្កើន/បន្ថយចំនួនកំណត់នៃទំហំឥណទាន

ម្ចាស់បណ្ណ ផ្តល់សិទ្ធិដោយគ្មានលក្ខខណ្ឌ និងមិនកំណត់ទៅឱ្យធនាគារក្នុងការសម្រេច ដោយឆន្ទានុសិទ្ធិរបស់ធនាគារ និងដោយពុំចាំបាច់ជូនដំណឹងជាមុន ថាតើត្រូវបង្កើន ឬបន្ថយចំនួនកំណត់ តាមការជ្រើសរើសរបស់ម្ចាស់បណ្ណ ទោះបីជាមាន/គ្មានការស្នើសុំពីម្ចាស់បណ្ណក៏ដោយ ឬក៏យោងទៅលើប្រវត្តិនៃគណនីនាពេលកន្លងមក ។ ពុំតម្រូវឱ្យមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរពីម្ចាស់បណ្ណឡើយ មុនពេលដែលធនាគារធ្វើការបង្កើន ឬបន្ថយចំនួនកំណត់ណាមួយ។ ធនាគារអាចនឹងជូនដំណឹងអំពីការកែប្រែនោះនាពេលក្រោយ ក្នុងករណីដែលធនាគារយល់ឃើញថាសមស្រប។

## វិធីទូទាត់ប្រាក់

### 18. ម្ចាស់បណ្ណ ត្រូវទូទាត់រាល់ថ្លៃប្រតិបត្តិការ ការប្រាក់ និងថ្លៃសេវាផ្សេងៗទៅឱ្យធនាគារឱ្យបានមុន ឬនៅថ្ងៃផុតកំណត់ ដែលមានបញ្ជាក់នៅក្នុងរបាយការណ៍

ការទូទាត់ប្រាក់ អាចធ្វើទៅបាននៅតាមសាខាណាមួយរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ តាមរយៈការទូទាត់ជាសាច់ប្រាក់សុទ្ធ មូលប្បទានបត្រ ឬតាមការផ្ទេរប្រាក់ពីគណនីផ្សេងៗដែលមាននៅក្នុងធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់។

មូលប្បទានបត្រ ត្រូវតែបានចេញឱ្យទូទាត់សងប្រាក់ដោយគ្រឹះស្ថានហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា។ ធនាគារ នឹងមិនទទួលយកមូលប្បទានបត្រដែលចេញឱ្យទូទាត់សងប្រាក់ដោយគ្រឹះស្ថានហិរញ្ញវត្ថុបរទេសឡើយ។

ការទូទាត់សងតាមរយៈការដកប្រាក់ដោយស្វ័យប្រវត្តិ ក៏អាចធ្វើបានដែរ ប្រសិនបើម្ចាស់បណ្ណចម្បង មានគណនីប្រាក់បញ្ញើជាមួយធនាគារ។ ម្ចាស់បណ្ណ ត្រូវតែប្រាកដថាគណនីដែលត្រូវបានកំណត់សម្រាប់ធ្វើការទូទាត់ ត្រូវតែមានសមតុល្យគ្រប់គ្រាន់សម្រាប់ទូទាត់រាល់ចំណាយនានា។

ប្រសិនបើគណនីដែលត្រូវ បានកំណត់សម្រាប់ធ្វើការទូទាត់នោះ មិនមានសមតុល្យគ្រប់គ្រាន់ដើម្បីទូទាត់ចំនួនទឹកប្រាក់ដែលត្រូវបង់ទេ នោះគ្មានការទូទាត់ទៅក្នុងបណ្ណឥណទានឡើយ ដូច្នេះម្ចាស់បណ្ណត្រូវទូទាត់ដោយផ្ទាល់ ឬមិន



Classified as Internal

ផ្ទាល់ នូវចំនួនសមតុល្យដែលនៅសល់ឱ្យបានទាន់ពេលវេលាកំណត់ និងទទួលបន្ទុករាល់ថ្លៃសេវាកម្ម និងការប្រាក់ទាំងអស់។

## 19. ចំនួនទឹកប្រាក់ត្រូវទូទាត់

ម្ចាស់បណ្ណ ត្រូវទទួលខុសត្រូវទូទាត់ចំនួនទឹកប្រាក់ដែលត្រូវបង់ទាំងអស់ឱ្យបានមុន ឬនៅថ្ងៃផុតកំណត់ដូចមានបញ្ជាក់នៅក្នុងរបាយការណ៍ប្រចាំខែដែលបានចេញជូនម្ចាស់បណ្ណ។ ប៉ុន្តែ ម្ចាស់បណ្ណ មានជម្រើសក្នុងការទូទាត់ចំនួនទឹកប្រាក់ដែលត្រូវបង់សរុប ឬចំនួនទឹកប្រាក់អប្បបរមា ឬក៏បង់ចំនួនទឹកប្រាក់ណាមួយក្នុងចន្លោះនៃចំនួនទឹកប្រាក់ដែលត្រូវបង់សរុប និងចំនួនទឹកប្រាក់អប្បបរមាទៅឱ្យធនាគារ។

ចំនួនទឹកប្រាក់អប្បបរមា ត្រូវបានគណនាដោយប្រើចំនួនទឹកប្រាក់ដូចខាងក្រោម៖

- ចំនួនទឹកប្រាក់ដែលត្រូវបង់ គុណនឹងភាគរយដែលបានកំណត់ទុកជាមុនដោយធនាគារ ឬក៏គុណនឹងចំនួនទឹកប្រាក់អប្បបរមាណាមួយដែលកំណត់ដោយអ្នកធនាគារ ដែលមានចំនួនខ្ពស់ជាង
- ចំនួនទឹកប្រាក់ដែលលើសពីចំនួនកំណត់នៃទំហំឥណទាន បូកនឹង
- ចំនួនទឹកប្រាក់ដែលហួលកាលកំណត់ត្រូវបង់ទាំងអស់ ប្រសិនបើមាន។

ប្រសិនបើថ្ងៃផុតកំណត់ប៉ះចំថ្ងៃសៅរ៍ អាទិត្យ ឬថ្ងៃបុណ្យជាតិ នោះការទូទាត់ប្រាក់ត្រូវធ្វើឡើងក្នុងថ្ងៃធ្វើការបន្ទាប់ពីថ្ងៃផុតកំណត់នោះ។

## 20. ការអនុវត្តការទូទាត់ប្រាក់

ការទូទាត់តាមរយៈគណនី ត្រូវធ្វើឡើងតាមលំដាប់ ដូចខាងក្រោម៖

- ថ្លៃសេវាកម្មដែលមិនទាន់បានទូទាត់ និង/ឬ ការប្រាក់ដែលបានបញ្ជាក់នៅក្នុងរបាយការណ៍ណាមួយ
- ថ្លៃសេវា និង/ឬ ការប្រាក់ដែលត្រូវទូទាត់ ប៉ុន្តែ ពុំទាន់បានបញ្ជាក់នៅក្នុងរបាយការណ៍ណាមួយ
- ប្រតិបត្តិការសាច់ប្រាក់ដែលបានបញ្ជាក់នៅក្នុងរបាយការណ៍ណាមួយ
- ប្រតិបត្តិការទិញទំនិញដែលបានបញ្ជាក់នៅក្នុងរបាយការណ៍ណាមួយ
- ប្រតិបត្តិការសាច់ប្រាក់ដែលបានធ្វើរួចហើយ ប៉ុន្តែមិនទាន់បញ្ជាក់នៅក្នុងរបាយការណ៍ណាមួយ
- ប្រតិបត្តិការទិញទំនិញដែលបានធ្វើរួចហើយ ប៉ុន្តែមិនទាន់មានបញ្ជាក់នៅក្នុងរបាយការណ៍ណាមួយ

ប្រសិនបើលោកអ្នកដាក់ប្រាក់ចូលក្នុងគណនីបណ្ណឥណទានរបស់លោកអ្នក តាមរយៈមូលប្បទានបត្រ ឬក៏តាមរបៀបដាក់ប្រាក់ផ្សេងទៀតដែលមិនមែនជាសាច់ប្រាក់ នោះធនាគារអាចពន្យារពេលការឱ្យប្រើប្រាស់ឥណទាននោះ រហូតដល់ពេលដែលចំនួនទឹកប្រាក់នោះត្រូវបានផាត់ទាត់រួចរាល់។ ប្រសិនបើលោកអ្នកមិនបានទូទាត់មូលប្បទានបត្រ ឬមិនបានធ្វើការដាក់ប្រាក់តាមរបៀបផ្សេងទៀតដែលមិនមែនជាសាច់ប្រាក់ ជាបន្តបន្ទាប់ នោះធនាគារ នឹងកាត់ប្រាក់ចេញពីគណនីបណ្ណឥណទាន តាមចំនួនដែលមិនបានទូទាត់នោះ (ប្រសិនបើបានដាក់ប្រាក់ចូលគណនីបណ្ណឥណទានកាលពីមុនរួចហើយ) និងគិតថ្លៃសេវាសម្រាប់ការមិនបានទូទាត់នេះ។

## 21. ប្រតិបត្តិការរូបិយប័ណ្ណបរទេស

ម្ចាស់បណ្ណ ត្រូវតែទូទាត់រាល់ប្រតិបត្តិការដែលចារឹកជារូបិយប័ណ្ណ ជាប្រាក់ដុល្លារអាមេរិច (USD)។ ធនាគារនឹងគិតថ្លៃសេវាកម្មប្តូរប្រាក់ក្នុងករណីនេះ។ អត្រាប្តូរប្រាក់ដែលយកមកប្រើ គឺជាអត្រាប្តូរប្រាក់តាមតម្លៃទីផ្សារទូទៅដែលជ្រើស



Classified as Internal

រើសដោយ Visa International មួយថ្ងៃមុនពេលដែលប្រតិបត្តិការនោះ ត្រូវបានដាក់ឱ្យដំណើរការ ដោយ Visa International។

## 22. អត្រាការប្រាក់

អត្រាភាគរយប្រចាំខែដែលត្រូវបានយកមកប្រើ ដើម្បីគណនាការប្រាក់សម្រាប់គណនី បណ្ណឥណទាន គឺមានបញ្ជាក់នៅក្នុងខិតប័ណ្ណផ្សព្វផ្សាយអំពីថ្លៃសេវា និងកម្រៃផ្សេងៗដែលអត្រានេះអាចនឹងមានការកែប្រែដោយធនាគារ នៅពេលណាមួយ។

## 23. រយៈពេលមិនគិតការប្រាក់ចំពោះប្រតិបត្តិការទិញទំនិញ

នៅក្នុងរបាយការណ៍នីមួយៗ មានបញ្ជាក់អំពី "សមតុល្យនៅពេលបិទបញ្ជី" និង "ថ្ងៃផុតកំណត់" របស់របាយការណ៍នោះ។ ដើម្បីទទួលបានអត្ថប្រយោជន៍ពីរយៈពេលមិនគិតការប្រាក់នេះ "សមតុល្យនៅពេលបិទបញ្ជី" ត្រូវតែធ្វើការទូទាត់ទាំងអស់ត្រឹម "ថ្ងៃផុតកំណត់" នៃរបាយការណ៍នីមួយៗ។

## 24. ការគណនាអត្រាការប្រាក់

ម្ចាស់បណ្ណ យល់ព្រមបង់ការប្រាក់ដែលមានចំពោះគណនីបណ្ណឥណទាន។ ការប្រាក់ត្រូវបានគណនា តាមរបៀបដូចខាងក្រោម៖

(ក) ប្រតិបត្តិការទិញទំនិញ ថ្លៃសេវា ការគិតថ្លៃផ្សេងៗ និងរាល់កំណត់ត្រាឥណពន្ធទាំងអស់ផ្សេងៗទៀតនៅក្នុងគណនី (មិនរួមបញ្ចូល ប្រតិបត្តិការសាច់ប្រាក់)៖ ប្រសិនបើម្ចាស់បណ្ណ ខកខានមិនបានទូទាត់សមតុល្យបំណុលដែលនៅសល់ទាំងអស់ នៅថ្ងៃផុតកំណត់ ឬមុនថ្ងៃផុតកំណត់ទេនោះ ម្ចាស់បណ្ណត្រូវទូទាត់ការប្រាក់ឱ្យទៅធនាគារ។ ការប្រាក់ ត្រូវបានគណនា ដោយគិតចាប់ពីថ្ងៃដែលបានធ្វើប្រតិបត្តិការ រហូតដល់ថ្ងៃដែលម្ចាស់បណ្ណបានទូទាត់សងគ្រប់ចំនួន។

(ខ) ប្រតិបត្តិការសាច់ប្រាក់៖ ការប្រាក់ ត្រូវបានគណនា ដោយគិតចាប់ពីថ្ងៃដែលប្រតិបត្តិការសាច់ប្រាក់ត្រូវបានកត់ត្រាឥណពន្ធនៅក្នុងគណនី រហូតដល់ថ្ងៃដែលម្ចាស់បណ្ណបានទូទាត់គ្រប់ចំនួន។

រាល់ការទូទាត់ ត្រូវបានកត់ត្រាឥណពន្ធនៅក្នុងគណនី តាមលំដាប់ដូចមានរៀបរាប់នៅក្នុងប្រការ ២០។

ធនាគារ មានសិទ្ធិក្នុងការកែប្រែអត្រាការប្រាក់ នៅគ្រប់ដំណាក់កាល តាមការសម្រេចចិត្តរបស់ខ្លួន។ ម្ចាស់បណ្ណ នឹងត្រូវបានជូនដំណឹងឱ្យបានដឹងជាមុន ក្នុងរយៈពេល ៣០ ថ្ងៃ អំពីការផ្លាស់ប្តូរណាមួយនៃអត្រាការប្រាក់។

## 25. ករណីបំពានកិច្ចព្រមព្រៀង

ម្ចាស់បណ្ណ ត្រូវបានចាត់ទុកថាបានបំពានកិច្ចព្រមព្រៀង ប្រសិនបើ៖

(ក) ម្ចាស់បណ្ណ មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង ក្នុងករណីដែលសមតុល្យបំណុលសរុប បានដល់ថ្ងៃកំណត់ត្រូវទូទាត់ដោយម្ចាស់បណ្ណ។

(ខ) ធនាគារ យល់ឃើញថា ការធ្វើសកម្មភាពណាមួយតាមរយៈការណែនាំរបស់ម្ចាស់បណ្ណ ឬការផ្តល់គណនី ឬសេវាណាមួយជូនម្ចាស់បណ្ណ អាចនាំឱ្យធនាគារបំពានច្បាប់ សេចក្តីសម្រេចដាក់ទណ្ឌកម្ម ឬលក្ខខណ្ឌតម្រូវជាធរមានណាមួយរបស់អាជ្ញាធរមានសមត្ថកិច្ច។



Classified as Internal

(គ) ម្ចាស់បណ្ណមិនបានផ្តល់ឱ្យធនាគារនូវព័ត៌មានដែលតម្រូវឱ្យមានស្របតាមការកំណត់នៅក្នុងលក្ខខណ្ឌនៃការប្រើប្រាស់ផលិតផលបណ្ណឥណទាននេះ ឬតាមការតម្រូវដោយច្បាប់ក្នុងស្រុក ឬ បរទេស និយ័តករ ស្ថាប័នរដ្ឋាភិបាល ឬអាជ្ញាធរប្រមូលចំណូល (ទោះបីក្នុងស្រុក ឬក្រៅស្រុកក្តី)។

ប្រសិនបើម្ចាស់បណ្ណមានគណនីច្រើនជាងមួយជាមួយធនាគារ នោះការបំពានកិច្ចព្រមព្រៀងនៃគណនីណាមួយ ត្រូវចាត់ទុកថាបានបំពានកិច្ចព្រមព្រៀងនៃគណនីផ្សេងទៀតផងដែរ។ ទោះក្នុងករណីណាក៏ដោយ ប្រសិនបើមានការបំពានកិច្ចព្រមព្រៀង ធនាគាររក្សាសិទ្ធិ បញ្ចប់គណនីទាំងអស់របស់ម្ចាស់បណ្ណដែលមានជាមួយអ្នកផ្តល់បណ្ណ។ ប្រសិនបើម្ចាស់បណ្ណមិនបានទូទាត់សមតុល្យបំណុលក្នុងអំឡុងពេល ៦០ថ្ងៃគិតចាប់ពីថ្ងៃជូនដំណឹងជាលាយលក្ខណ៍អក្សរដោយធនាគារ អំពីការបំពានកិច្ចព្រមព្រៀងរបស់ម្ចាស់បណ្ណ៖

(ក) ប្រសិនបើម្ចាស់បណ្ណ បានដាក់គណនីប្រាក់បញ្ញើធ្វើជាទ្រព្យធានា នោះម្ចាស់បណ្ណ ត្រូវបានចាត់ទុកថាផ្តល់សិទ្ធិ និងអនុញ្ញាតឱ្យធនាគារ មានសិទ្ធិដកប្រាក់ចេញពីគណនី ប្រាក់បញ្ញើ/សន្សំ របស់ម្ចាស់បណ្ណដែលមានជាមួយធនាគារ ដោយមិនចាំបាច់មានការយល់ព្រម ឬបញ្ជាក់ពីម្ចាស់បណ្ណ ដើម្បីទូទាត់សមតុល្យបំណុលណាមួយ ឬទាំងអស់ឡើយ

(ខ) ប្រសិនបើម្ចាស់បណ្ណបានផ្តល់ “ការធានាដោយក្រុមហ៊ុន” ដើម្បីជាការធានាឥណទាន នោះម្ចាស់បណ្ណ ត្រូវបានចាត់ទុកថាផ្តល់សិទ្ធិទៅឱ្យធនាគារក្នុងការទាមទារប្រាក់ដើម្បីទូទាត់សមតុល្យបំណុលពីក្រុមហ៊ុន ដែលបានផ្តល់ការធានាចំពោះគណនីរបស់ម្ចាស់បណ្ណ ដោយមិនចាំបាច់មានការយល់ព្រម និងការបញ្ជាក់បន្ថែមពីម្ចាស់បណ្ណទៀតឡើយ។

បន្ទាប់ពីមានការបំពានកិច្ចព្រមព្រៀងកើតមានឡើង ម្ចាស់បណ្ណយល់ព្រមឱ្យធនាគារអាចចាត់វិធានការខាងក្រោមណាមួយ ឬច្រើន តាមឆន្ទានុសិទ្ធិរបស់ធនាគារ ៖

(ក) បញ្ចប់សិទ្ធិប្រើប្រាស់បណ្ណ ហើយបន្ទាប់មក ចាប់ផ្តើមវិធានការទាមទារមកវិញនូវសមតុល្យបំណុលបទាំងអស់

(ខ) គិតថ្លៃសេវានៃការទូទាត់សងយឺតយ៉ាវ និង/ឬថ្លៃសេវានៃការប្រើប្រាស់លើសចំនួនកំណត់ ដែលបានកំណត់ដោយធនាគារ

(គ) ចាត់វិធានការមួយ ឬច្រើន ដើម្បីទាមទារ/ប្រមូលបំណុល ដែលអាចរាប់បញ្ចូលទាំងវិធានការផ្លូវច្បាប់ផងដែរ និង

(ឃ) ចុះឈ្មោះរបស់ម្ចាស់បណ្ណទៅក្នុងបញ្ជីឈ្មោះអ្នកដែលបានបំពានកិច្ចព្រមព្រៀ(ឬបញ្ជីឈ្មោះប្រហាក់ប្រហែលណាមួយ) ដែលបញ្ជីឈ្មោះនេះគ្រប់គ្រងដោយធនាគារ ស្ថាប័នរដ្ឋាភិបាល ឬស្ថាប័នផ្សេងទៀត តាមឆន្ទានុសិទ្ធិរបស់ធនាគារ ឬ តាមការតម្រូវដោយច្បាប់។

# ថ្លៃសេវា

## 26. ថ្លៃសេវា

បន្ថែមពីលើការប្រាក់ ម្ចាស់បណ្ណត្រូវតែបង់ថ្លៃសេវា និងកម្រៃផ្សេងៗទៀតដែលពាក់ព័ន្ធនឹងបណ្ណ រួមមានដូចជាថ្លៃសេវាខាងក្រោមនេះ៖

(ក) ថ្លៃសេវាប្រចាំឆ្នាំ ថ្លៃសេវាសម្រាប់បណ្ណបន្ថែម៖ ត្រូវបានគិតមួយឆ្នាំម្តង



Classified as Internal

(ខ) ថ្លៃសេវាចំពោះការដកជាសាច់ប្រាក់សុទ្ធ៖ ត្រូវបានគិតនៅពេលដែលម្ចាស់បណ្ណដកប្រាក់ពីម៉ាស៊ីនATM ឬធនាគារ ឬស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត

(គ) ថ្លៃសេវាប្តូររូបិយប័ណ្ណបរទេស៖ ត្រូវបានគិតចំពោះប្រតិបត្តិការប្តូររូបិយប័ណ្ណបរទេស ទៅជាប្រាក់ដុល្លារអាមេរិក និងអាស្រ័យទៅលើប្រតិបត្តិការរូបិយប័ណ្ណបរទេស និងពេលវេលាដែលប្រតិបត្តិការដែលត្រូវបានកត់ត្រាឥណពន្ធទៅក្នុងគណនី

(ឃ) ថ្លៃសេវាចំពោះការប្រើប្រាស់លើសពីចំនួនកំណត់៖ ត្រូវបានគិតចំពោះសមតុល្យបំណុល ដែលលើសចំនួនកំណត់ទាំងអស់

(ង) ថ្លៃសេវាចំពោះការបង់យឺតយ៉ាវ៖ ត្រូវបានគិត ប្រសិនបើម្ចាស់បណ្ណមិនបានបង់ យ៉ាងហោចណាស់ ចំនួនទឹកប្រាក់អប្បបរមា ឱ្យបានមុន ឬនៅថ្ងៃផុតកំណត់

(ច) ថ្លៃសេវាចំពោះការថតចម្លងរបាយការណ៍៖ ត្រូវបានគិត នៅពេលដែលម្ចាស់បណ្ណ ស្នើសុំច្បាប់ចម្លងនៃរបាយការណ៍ច្បាប់ដើម

(ឆ) ថ្លៃសេវាចំពោះការស្នើសុំឱ្យសងប្រាក់ដែលទូទាត់ខុសមកវិញ៖ ត្រូវបានគិត តាមឆន្ទានុសិទ្ធិរបស់ធនាគារ នៅពេលដែលម្ចាស់បណ្ណស្នើសុំឱ្យបង្វិលប្រាក់សងវិញ ដោយហេតុថាការទូទាត់នោះមានភាពមិនត្រឹមត្រូវ

(ជ) ថ្លៃសេវាសម្រាប់ការប្តូរបណ្ណ៖ ត្រូវបានគិត នៅពេលម្ចាស់បណ្ណស្នើសុំប្តូរបណ្ណមុនកាលបរិច្ឆេទផុតកំណត់

(ឈ) ថ្លៃសេវាចំពោះការមិនទូទាត់មូលប្បទានបត្រ៖ ត្រូវគិតពីគណនីរបស់ម្ចាស់បណ្ណ ក្នុងករណីដែលពុំមានការទូទាត់ណាមួយពីគណនីរបស់លោកអ្នក ដោយហេតុថាមូលប្បទានបត្ររបស់លោកអ្នកពុំមានប្រាក់គ្រប់គ្រាន់ ដើម្បីធ្វើការទូទាត់

(ញ) ថ្លៃសេវាសម្រាប់ការស្នើសុំករណីលើកលែង៖ ត្រូវបានគិត នៅពេលម្ចាស់បណ្ណស្នើសុំបន្ថែម ឬស្នើសុំករណីពិសេសណាមួយពីអ្នកផ្តល់បណ្ណ។ ថ្លៃសេវាកម្មនេះ អាចមានតម្លៃខុសគ្នាទៅតាមប្រភេទនៃការស្នើសុំ និងអាចត្រូវបានគិតបញ្ចូលទាំងថ្លៃសេវាកម្មសម្រាប់ការផ្ញើបណ្ណដែលផ្លាស់ប្តូរថ្មីទៅបរទេស។

ថ្លៃសេវា អាចត្រូវបានគិតដោយផ្អែកលើភាគរយដែលត្រូវបានកំណត់ទុកជាមុននៃតម្លៃប្រតិបត្តិការ/សមតុល្យ ឬថ្លៃសេវាអប្បបរមាថេរ ឬក៏ផ្អែកលើកត្តាទាំងពីរនេះ។

ថ្លៃសេវាកម្មទាំងអស់ នឹងត្រូវបានដកចេញពីគណនីភ្លាមៗ ឬក៏កត់ត្រាចូលរបាយការណ៍នៅគ្រាបន្ទាប់។

ព័ត៌មានលម្អិតនៃថ្លៃសេវាកម្មខាងលើ ក៏មានកំណត់នៅក្នុងតារាងថ្លៃសេវាកម្មរបស់ធនាគារផងដែរ។ ធនាគារ រក្សាសិទ្ធិកែប្រែរចនាសម្ព័ន្ធថ្លៃសេវា ឬថ្លៃសេវាណាមួយ។ ធនាគារ នឹងជូនដំណឹងដល់ម្ចាស់បណ្ណជាមុន ចំនួន ៣០ ថ្ងៃ អំពីការផ្លាស់ប្តូរថ្លៃសេវាកម្ម និងថ្លៃផ្សេងៗ ដូចមានពន្យល់លម្អិតនៅក្នុងតារាងថ្លៃសេវាកម្មរបស់អ្នកផ្តល់បណ្ណ។

## លក្ខខណ្ឌផ្សេងៗ

### 27. បណ្ណបន្ថែម

ម្ចាស់បណ្ណចម្បង អាចប្រគល់សិទ្ធិឱ្យធនាគារក្នុងការចេញបណ្ណបន្ថែម ដែលក្នុងករណីនេះធនាគារអាចគិតថ្លៃសេវាចំពោះការចេញបណ្ណបន្ថែមនេះ។ ម្ចាស់បណ្ណបន្ថែម ត្រូវតែមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ។



Classified as Internal

ចំនួនបណ្ណបន្ថែមអាចខុសគ្នាអាស្រ័យលើគោលនយោបាយដែលមានស្រាប់របស់អ្នកផ្តល់បណ្ណ។ការចេញបណ្ណបន្ថែម គឺជាសិទ្ធិសម្រេចចិត្តបស់ធនាគារតែម្នាក់ប៉ុណ្ណោះ។

ការប្រើប្រាស់បណ្ណបន្ថែម ត្រូវជូនដំណឹង និងមានការអនុញ្ញាតពីម្ចាស់បណ្ណចម្បង។ ម្ចាស់បណ្ណចម្បង អាចស្នើសុំដក សិទ្ធិប្រើប្រាស់បណ្ណបន្ថែមដែលជាប់ទាក់ទងនឹងគណនីរបស់ខ្លួនបាន ដោយទាក់ទងមកកាន់ធនាគារតាមរយៈការហៅទូរសព្ទ ឬក៏ជាលាយលក្ខណ៍អក្សរ។ ធនាគារ នឹងដកសិទ្ធិប្រើប្រាស់បណ្ណបន្ថែម តែនៅពេលណាដែលម្ចាស់បណ្ណចម្បង បានប្រគល់បណ្ណមកឱ្យ ធនាគារវិញ ឬនៅពេលណាដែលម្ចាស់បណ្ណចម្បង បានចាត់វាល់វិធានការសមស្របដើម្បីប្រគល់បណ្ណនោះមកឱ្យធនាគារវិញ។

## 28. ការកែប្រែលក្ខខណ្ឌដោយឡែកនេះ

បន្ទាប់ពីមានការជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬតាមមធ្យោបាយផ្សេងទៀត ឱ្យម្ចាស់បណ្ណបានដឹងជាមុន ក្នុងរយៈពេល ៣០ ថ្ងៃ ធនាគារអាចធ្វើវិសោធនកម្ម កែប្រែ ឬផ្លាស់ប្តូរលក្ខខណ្ឌដោយឡែកទាំងនេះ បានគ្រប់ពេលវេលា និងនៅគ្រប់កាលៈទេសៈដែលសមស្រប ហើយការធ្វើវិសោធនកម្មនេះ ត្រូវចងកាតព្វកិច្ចចំពោះម្ចាស់បណ្ណ លើកលែងតែម្ចាស់បណ្ណធ្វើការបដិសេធ ដោយបង្ហាញឆន្ទៈបញ្ចប់កិច្ចព្រមព្រៀង ស្របតាមលក្ខខណ្ឌដែលមានចែងនៅក្នុងប្រការ ១៤។

## 29. ការលើកលែងចំពោះការបំពានកិច្ចព្រមព្រៀង

ការលើកលែងណាមួយដោយធនាគារចំពោះការរំលោភបំពាន ឬការមិនគោរព លក្ខខណ្ឌដោយឡែកទាំងនេះ មិនត្រូវចាត់ទុកថាជាការលើកលែងចំពោះការរំលោភបំពាន ឬការមិនគោរពខចែង ឬលក្ខខណ្ឌផ្សេងទៀតដែលស្រដៀងគ្នាឡើយ។ ការខកខានណាមួយដោយធនាគារក្នុងការទទួលប្រយោជន៍ ឬប្រើប្រាស់សិទ្ធិណាមួយដែលមានចែងនៅក្នុងលក្ខខណ្ឌនេះ មិនត្រូវចាត់ទុកថាជាការលើកលែង/បោះបង់សិទ្ធិនោះឡើយ និងមិនត្រូវចាត់ទុកជាការលើកលែង ឬការឱ្យម្ចាស់បណ្ណរួចផុតពីការប្រតិបត្តិតាម ឬការបំពេញកាតព្វកិច្ចតាមកិច្ចព្រមព្រៀងឡើយ។

## 30. ស្វ័យភាពនៃលក្ខខណ្ឌ

ប្រសិនបើលក្ខខណ្ឌដោយឡែកណាមួយដែលចែងនៅក្នុងនេះ ឬផ្នែក ឬប្រការណាមួយ ត្រូវបានប្រកាសជាមោឃៈ ឬមិនអាចអនុវត្តបាន ដោយអាជ្ញាធរមានសមត្ថកិច្ច នោះលក្ខខណ្ឌទាំងនេះនឹងមិនមានការប៉ះពាល់ដល់សុពលភាពនៃលក្ខខណ្ឌ ផ្នែក ឬប្រការផ្សេងទៀតឡើយ ហើយកិច្ចព្រមព្រៀងនេះ ត្រូវបានចាត់ទុកថាមិនមានចែងអំពីលក្ខខណ្ឌ សិទ្ធិ និងកាតព្វកិច្ចទាំងនោះ ហើយសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកប្រើប្រាស់បណ្ណ និងធនាគារ កិច្ចព្រមព្រៀងនឹងនៅតែបន្តមានអានុភាពអនុវត្តដដែល។

## 31. បណ្ណដែលមានកិច្ចធានា

ធនាគារអាចរៀបចំឱ្យម្ចាស់បណ្ណផ្តល់កិច្ចធានាមួយ ឬច្រើន ដើម្បីជានាកាតព្វកិច្ចទូទាត់បំណុលរបស់ម្ចាស់បណ្ណតាមកិច្ចព្រមព្រៀង។ ប្រសិនបើបណ្ណដែលមានកិច្ចធានា ត្រូវបានចេញឱ្យធនាគារ នោះទម្រង់នៃការធានាដែលផ្តល់ឱ្យធនាគារ ត្រូវមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរ ហើយឯកសារណាមួយដែលមានការពាក់ព័ន្ធ ត្រូវចាត់ទុកជាផ្នែកមួយនៃកិច្ចព្រមព្រៀង។



Classified as Internal

## 32. ពន្ធ

ធនាគារអាចតម្រូវឱ្យកាត់ទុកនូវចំនួនទឹកប្រាក់ដែល ទូទាត់ទៅឱ្យម្ចាស់គណនីមួយចំនួនរួចហើយផ្ទេរទឹកប្រាក់នោះទៅឱ្យស្ថាប័នរដ្ឋាភិបាលក្នុងស្រុក ឬបរទេស ឬអាជ្ញាធរប្រមូលចំណូល យោងតាមច្បាប់ក្នុងស្រុក ឬបរទេស ឬតាមរយៈកិច្ចព្រមព្រៀងជាមួយនឹងអាជ្ញាធរទាំងនោះ។

ប្រសិនបើនៅពេលណាមួយ ស្ថាប័នរដ្ឋាភិបាលក្នុងស្រុក ឬបរទេស ឬអាជ្ញាធរប្រមូលចំណូល តម្រូវឱ្យធនាគារធ្វើការកាត់ទុក ឬដកចំនួនទឹកប្រាក់ណាមួយដែលត្រូវបង់ដោយម្ចាស់បណ្ណ នោះម្ចាស់បណ្ណយល់ព្រមភ្លាមក្នុងការសងធនាគារវិញ នូវចំនួនទឹកប្រាក់នៃការកាត់ទុក ឬដកទុកនោះ រួមទាំងអនុញ្ញាតឱ្យធនាគារកាត់ទឹកប្រាក់ទាំងនោះពីគណនីលោកអ្នកផងដែរ។ ម្ចាស់បណ្ណ ត្រូវចេញសងធនាគារចំពោះការខាតបង់ ឬការចំណាយរបស់ធនាគារ ដែលបានកើតឡើងដោយសារការកាត់ទុក ឬការដកទុកនោះ។

## 33. ពន្យល់ពាក្យ

(1) **បណ្ណបន្ថែម៖** គឺជាបណ្ណឥណទានបន្ថែមដែលចេញក្រោមគណនីតែមួយរបស់ម្ចាស់បណ្ណចម្បង សម្រាប់ម្ចាស់បណ្ណបន្ថែមយកទៅប្រើប្រាស់ទៅតាមការកំណត់របស់ម្ចាស់បណ្ណចម្បង។

(2) **ម្ចាស់បណ្ណបន្ថែម៖** គឺជាបុគ្គលដែលចាត់តាំងដោយម្ចាស់បណ្ណចម្បងឱ្យប្រើប្រាស់បណ្ណបន្ថែមដែលចេញដោយធនាគារ។ ម្ចាស់បណ្ណបន្ថែម ត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នាចំពោះប្រតិបត្តិការ ការប្រាក់ សោហ៊ុយ និងចំណាយទាំងអស់ដែលពាក់ព័ន្ធនឹងគណនី។

(3) **អ្នកស្នើសុំបណ្ណ៖** គឺជាបុគ្គលដែលចង់ក្លាយខ្លួនជាម្ចាស់បណ្ណថ្មី។

(4) **ពាក្យស្នើសុំ ៖** គឺជាទម្រង់បែបបទដែលត្រូវបំពេញ និងដាក់ជូនធនាគារដើម្បីអាចឱ្យធនាគារ សម្រេចចិត្តថាតើគួរតែអនុម័តឱ្យអ្នកស្នើសុំបណ្ណអាចក្លាយខ្លួនជាម្ចាស់បណ្ណដែរឬទេ ហើយពាក្យស្នើសុំនេះ គឺជាផ្នែកមួយនៃកិច្ចព្រមព្រៀងរវាងធនាគារ និងអតិថិជន។

(5) **ចំនួនទឹកប្រាក់ដែលត្រូវបង់៖** ជាចំនួនទឹកប្រាក់ដែលនៅសល់នៅក្នុងបណ្ណដែលម្ចាស់បណ្ណត្រូវតែបង់ទៅឱ្យធនាគារនៅថ្ងៃផុតកំណត់ ឬ មុនថ្ងៃផុតកំណត់ ដែលចំនួននេះអាចរួមបញ្ចូលទាំងចំនួនទឹកប្រាក់អប្បបរមាដែលត្រូវបង់ ចំនួនទឹកប្រាក់ដែលហួសកាលកំណត់ត្រូវបង់ ចំនួនទឹកប្រាក់ដែលលើសពីចំនួនកំណត់ សោហ៊ុយចំពោះទឹកប្រាក់ដែលលើសពីចំនួនកំណត់ និងសោហ៊ុយផ្សេងៗទៀតដែលអាចកើតមានចេញគណនីនេះ។

(6) **ម្ចាស់បណ្ណ៖** រួមមានម្ចាស់បណ្ណចម្បង និង/ឬម្ចាស់បណ្ណបន្ថែម។ នៅក្រោមក្ខខណ្ឌនៃការប្រើប្រាស់បណ្ណឥណទាននេះម្ចាស់បណ្ណ គឺអាចជាម្ចាស់បណ្ណចម្បង ឬម្ចាស់បណ្ណបន្ថែម ឬក៏ទាំងម្ចាស់បណ្ណចម្បង និងម្ចាស់បណ្ណបន្ថែម។

(7) **ប្រតិបត្តិការសាច់ប្រាក់៖** គឺជាការប្រើប្រាស់បណ្ណដោយម្ចាស់បណ្ណ ក្នុងការដកសាច់ប្រាក់ចេញពីម៉ាស៊ីន អេ.ធី.អឹម ដកចេញពីធនាគារ ឬពីស្ថាប័នហិរញ្ញវត្ថុផ្សេងៗទៀត។

(8) **ការធានាដោយក្រុមហ៊ុន៖** គឺជាការធានាដោយក្រុមហ៊ុនចំពោះកាតព្វកិច្ចរបស់ម្ចាស់បណ្ណ ដូចមានកំណត់នៅក្នុងលក្ខខណ្ឌនៃកិច្ចព្រមព្រៀង ដោយត្រូវចុះកិច្ចព្រមព្រៀងមួយដែលមានបីភាគីចូលរួម រួមមាន ក្រុមហ៊ុន ម្ចាស់បណ្ណ និងធនាគារ ។

(9) **បណ្ណឥណទាន** (តទៅហៅកាត់ថា “**បណ្ណ**”)៖ គឺជាបណ្ណឥណទានដែលចេញដោយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ។



Classified as Internal

(10) **គណនីបណ្ណឥណទាន** (តទៅហៅកាត់ថា “**គណនី**”)៖ គឺជាគណនីដែលបានបើក ដោយយោងតាមកិច្ចព្រមព្រៀងរបស់ធនាគារ ក្នុងគោលបំណងដើម្បីគ្រប់គ្រងប្រតិបត្តិការដែលពាក់ព័ន្ធនឹងបណ្ណ។ ម្ចាស់បណ្ណបន្ថែមក៏ត្រូវស្ថិតនៅក្នុងគណនីតែមួយដូចគ្នានឹងម្ចាស់បណ្ណចម្បងផងដែរ។

(11) **កិច្ចព្រមព្រៀងបណ្ណឥណទាន** (តទៅហៅកាត់ថា “**កិច្ចព្រមព្រៀង**”)៖ កិច្ចព្រមព្រៀង រួមមានលក្ខខណ្ឌដោយឡែកនៃការប្រើប្រាស់នេះ និងពាក្យស្នើសុំដែលត្រូវបានចុះហត្ថលេខារួចរាល់។

(12) **ចំនួនកំណត់នៃទំហំឥណទាន** (តទៅហៅកាត់ថា “**ចំនួនកំណត់**”)៖ គឺជាកម្រិតអតិបរមានៃចំនួនឥណទាន នៅក្នុងបណ្ណដែលត្រូវបានអនុម័តដោយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់។

(13) **ទ្រព្យធានាជាគណនីប្រាក់បញ្ញើ**៖ គឺជាគណនីប្រាក់បញ្ញើ គណនីប្រាក់សន្សំ និង/ឬគណនីប្រាក់បញ្ញើមានកាលកំណត់ ដែលត្រូវបានម្ចាស់បណ្ណយកមកបង្កើតជាការធានាចំពោះការអនុវត្តកាតព្វកិច្ចរបស់ម្ចាស់បណ្ណដែលមាននៅក្នុងលក្ខខណ្ឌនៃកិច្ចព្រមព្រៀង។

(14) **ថ្ងៃផុតកំណត់**៖ គឺជាថ្ងៃកំណត់ដែលម្ចាស់ប័ណ្ណត្រូវតែធ្វើការទូទាត់ចំនួនទឹកប្រាក់ដែលត្រូវបង់ ឬចំនួនទឹកប្រាក់អប្បបរមា។

(15) **ពាណិជ្ជករ**៖ គឺជានីតិបុគ្គល ឬរូបវន្តបុគ្គលដែលត្រូវបានគេផ្ដល់សិទ្ធិឱ្យទទួលយកបណ្ណ ដើម្បីធ្វើជាមធ្យោបាយទូទាត់ថ្លៃទំនិញ និង/ឬសេវាកម្មនានា។

(16) **ចំនួនទឹកប្រាក់អប្បបរមាដែលត្រូវបង់** (តទៅហៅកាត់ថា “**ចំនួនទឹកប្រាក់អប្បបរមា**”) គឺជាចំនួនទឹកប្រាក់អប្បបរមានៃបំណុលដែលមានជំពាក់នៅក្នុងបណ្ណ ដូចមានបង្ហាញនៅក្នុងរបាយការណ៍ ដែលម្ចាស់បណ្ណត្រូវតែបង់ចំនួនទឹកប្រាក់នេះ នៅថ្ងៃកំណត់ ឬមុនថ្ងៃកំណត់។

(17) **ចំនួនទឹកប្រាក់ដែលលើសចំនួនកំណត់**៖ គឺជាសមតុល្យនៅសល់ដែលលើសពីចំនួនកំណត់។

(18) **ម្ចាស់បណ្ណចម្បង**៖ គឺជាបុគ្គលដែលមានឈ្មោះនៅក្នុងគណនីដែលបានបើក និងជាអ្នកដែលទទួលខុសត្រូវចំពោះរាល់ប្រតិបត្តិការ រួមទាំង ថ្លៃសេវា និងសោហ៊ុយផ្សេងៗដែលកើតចេញពីគណនីនេះ។

(19) **ប្រតិបត្តិការទិញទំនិញ**៖ គឺជាការប្រើប្រាស់បណ្ណដោយម្ចាស់បណ្ណ ដើម្បីធ្វើការទូទាត់ថ្លៃទំនិញ និង/ឬថ្លៃសេវាកម្មផ្សេងៗ។

(20) **ទ្រព្យធានា**៖ គឺជាសាច់ប្រាក់ ឬទ្រព្យធានាផ្សេងទៀតដែលម្ចាស់បណ្ណត្រូវយកមកដាក់ដើម្បីជានាកាតព្វកិច្ចបង់ប្រាក់របស់ខ្លួន ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ដោយត្រូវមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីសំណាក់អ្នកផ្ដល់បណ្ណ។

(21) **របាយការណ៍គណនី** (តទៅហៅកាត់ថា “**របាយការណ៍**”) គឺជាឯកសារសង្ខេបដែលធនាគារចេញឱ្យម្ចាស់បណ្ណដោយក្នុងនោះមានរៀបរាប់អំពីប្រតិបត្តិការនានា ការប្រាក់ ថ្លៃសេវាកម្ម ឥណទាន ការចំណាយ ការកែតម្រូវនានា (បើមាន) និងចំនួនទឹកប្រាក់អប្បបរមាដែលត្រូវបង់ទៅឱ្យម្ចាស់បណ្ណ។

(22) **ប្រតិបត្តិការ**៖ រួមមានប្រតិបត្តិការទិញទំនិញ និងប្រតិបត្តិការសាច់ប្រាក់។

(23) **បញ្ចប់**៖ សំដៅដល់ ផ្អាក បញ្ឈប់ ឬលុបចោលការប្រើប្រាស់បណ្ណ ដោយរួមបញ្ចូលទាំងសិទ្ធិ និងលក្ខណៈពិសេសទាំងអស់របស់បណ្ណផងដែរ។



Classified as Internal

(24)“**លោកអ្នក**” មានន័យថាជាម្ចាស់បណ្ណម្នាក់/ច្រើន និងអ្នកទទួលបានសិទ្ធិប្រើប្រាស់ “**របស់លោកអ្នក**” មានអត្ថន័យទាក់ទងនឹងពាក្យនេះ) លើកលែងតែមានការកំណត់ផ្សេងពីនេះ។

**ទំនាក់ទំនងមកកាន់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក**

**តាមរយៈទូរសព្ទលេខ:**

ក្នុងស្រុក 023 999 000

អន្តរជាតិ +855 23 999 000 (247)

អ៊ីមែល: ccc@jtrustroyal.com

គេហទំព័រ: www.jtrustroyal.com

SWIFT: TCABKHPP



Classified as Internal